ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ០៨

ចុះថ្ងៃទី១៥ខែមករាឆ្នាំ១៩៩៩

សាលដីកា

លេខ :១៦៩

ចុះថ្ងៃទី១៤ខែកញ្ញាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី ១៥ ខែ កញ្ញា- ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :-

១_ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២_លោក ប៉េន ស៊ិន ជាចៅក្រម

៣_លោក ទៀល មួន ជាចៅក្រម

៤_លោក ជីវ កេង ជាចៅក្រម

៥_លោក យស់ សួនឡឿន ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី ហុត សុគន្ធា

តំណាងមហាអយ្យការ

លោក ប៉េន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៧៥០ ចុះថ្ងៃទី ៣០_១១_៩៨ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ៣៨៤ ចុះថ្ងៃទី ១២_១០_៩៨ របស់ សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ សេង ហុង អាយុ ២៦ ឆ្នាំ ជាតិ ខ្មែរ ភេទ ប្រុស មុខរបរ និស្សិត ទីលំនៅ ផ្ទះលេខ ១២ អឺ០ ផ្លូវលេខ ៩៩ក្រុម ១៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ សេង ឡាង "ស", ម្តាយឈ្មោះ ពេជ លុន "ស" ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ អៀង ថុង អាយុ ៤១ឆ្នាំ ជាតិខ្មែរ ភេទប្រុស មុខរបរលក់ទឹកកក ទីលំនៅផ្ទះលេខ ៨៥ស្ទួន ផ្លូវ ៩៩ ក្រុម ១៨ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ អៀង ហួត "ស", ម្តាយឈ្មោះ ហុក ហួយ ។

តាមបណ្តឹងសាទុក្ខលេខ៤១៩ ចុះថ្ងៃទី០៧_១២_៩៨ របស់លោក សេង ហុង ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ ៧៥០ ចុះថ្ងៃទី ៣០_១១_៩៨ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ០៨ ចុះថ្ងៃទី១៥_០១_៩៩ របស់តុលាការកំពូល

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៦ របស់លោក អៀង ថុង

ថាខ្លួនប្តឹងទាមទារសំណងការអន្តរាយបណ្តាលមកពីអគ្គិភ័យ ចំនួន ៦០ តម្លឹងមាសពីឈ្មោះ សេង ហុង ដោយកាលពីថ្ងៃទី ២៥-០១-៨៣ មានអគ្គិភ័យកើតឡើងពីផ្ទះរបស់ឈ្មោះ សេង ហុង ធ្វើអោយឆេះផ្ទះ និង សម្ភារៈរបស់ខ្លួនអស់ជាច្រើនពីព្រោះពេលកើតហេតុនោះឈ្មោះ សេង ហុង ចេញផុតពីផ្ទះប្រហែល ៥នាទី ភ្លើងក៏ឆេះឡើងភ្លាម ពេលនោះផ្ទះរបស់ឈ្មោះ សេង ហុង ចាក់សោរចោល ក្រុមប៉ូលីសការពារទូតរកវាយសោរចូលពន្លត់ភ្លើង តែឪពុករបស់ សេង ហុង ពុំព្រមអោយវាយសោរនោះទេ ។ ផ្ទះរបស់ខ្លួននៅខាងលើ ហើយផ្ទះរបស់ក្រុមគ្រួសារ សេង ហុង នៅខាងក្រោម ៕

ឈ្មោះ សេង ហុង បានឆ្លើយថា កាលពីថ្ងៃទី ២៥-០១-៨៣ មានអគ្គិភ័យកើតឡើងបណ្តាលអោយឆេះផ្ទះរបស់ខ្លួន និង ផ្ទះរបស់ថៅកែអៀង ថុង អស់ នៅពេលនោះខ្លួនមិនដឹងថាភ្លើងនោះឆេះបណ្តាលមកពីផ្ទះអ្នកណាមុនទើបឡើយ ពីព្រោះនៅពេលកើតហេតុនោះ ផ្ទះរបស់ខ្លួនបានចាក់សោរទុកចោល ហើយក្រុមគ្រួសាររបស់ខ្លួនបានទៅលេងផ្ទះបង ប្អូនជីដូនមួយអស់ទៅហើយ ខ្លួនមិនអាចសងសំណងការខូចខាតភ្លើងឆេះផ្ទះនេះអោយទៅឈ្មោះ អៀង ថុង បានឡើយ ៕

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៥៧ "ក" ចុះថ្ងៃទី ២០-០៥-៨៨ របស់ តុលាការ-ក្រុងភ្នំពេញ ដែលបានសម្រេចដូចតទៅ :-

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ អៀង ថុង ចុះថ្ងៃទី ២៦-០៤-៨៦ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ៕

២-បង្គាប់អោយឈ្មោះ សេង ហុង សងការខូចខាតអន្តរាយ ដល់ឈ្មោះ អៀង ថុង ចំនួន ៥០តម្លឹងមាសសុទ្ធ និង ប្រាក់ជម្ងឺចិត្តចំនួន ៥.០០០ដុល្លាអាមេរិក ឈ្មោះ អៀង ថុង ទាមទារលើសពីនេះបដិសេធចោល តាមមាត្រា ១២១ និង ១២៨ នៃក្រឹត្យច្បាប់លេខ៣៨ក្រ-ច ចុះថ្ងៃ-ទី ២៨-១០-៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ៕ ក្នុងករណីឈ្មោះសេងហុងគ្មានប្រាក់សង សំរេចរឹបអូសទ្រព្យសម្បត្តិរបស់ចុងចម្លើយដើម្បីលក់ឡាយឡុងនាំសំណង ៕

៣-បង្គាប់អោយឈ្មោះ សេង ហុង បង់ប្រាក់ប្រដាប់ក្តី គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ុង ចំនួន ១.៨០០៛០០រង្វាន់ក្រឡាបញ្ជីកាន់បញ្ជីប្រាក់ ២០០៛០០ រង្វាន់អ្នកប្រគល់ដីកាកោះ២.០០០៛០០ រង្វាន់សាក្សី ៣.០០០៛០០ សរុប ៧.០០០៛០០ ប្រាក់នេះបានកាត់យកពីប្រាក់ ដែលដើមចោទបានបង់ទុករួចជាស្រេច ៕

កាលបើហួសឧទ្ធរណ៍ បង្គាប់អោយឈ្មោះ សេង ហុង សងប្រាក់ ៧.០០០៛០០ អោយឈ្មោះ អៀង ថុង វិញ និង បង្គាប់អោយបង់ពន្ធសមាមាត្រមួយភាគរយលើប្រាក់ ៥០ តម្លឹងមាសសុទ្ធ និង ប្រាក់ជម្ងឺចិត្តចំនួន ៥.០០០ដុល្លាអាមេរិក ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន ៨០ភាគរយ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ៕

៤-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូភាគី សំរេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

សាលក្រមនេះត្រូវបានឈ្មោះលោក សេង ហុង ប្ដឹងឧទ្ធរណ៍តាមបណ្ដឹងចុះថ្ងៃទី ២៧ ខែឧសភាឆ្នាំ ១៩៩៨ លើសេចក្ដីសំរេច នៃ សាលក្រមទាំងមូល ។

បានឃើញសាលដីកាលេខ ៧៥០ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃ សេចក្ដីសំរេចដូចតទៅ :-

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២៧-០៥-១៩៩៨ របស់ឈ្មោះ សេង ហុង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៥៧ "ក" ចុះថ្ងៃទី ២០-០៥-៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ប៉ុន្តែលើកលែងត្រង់ចំណុចសងការខូចខាត ត្រូវកែប្រែពី ៥០តម្លឹង "ហាសិបតម្លឹង" មក ៤៥ តម្លឹងមាស "សែសិបប្រាំតម្លឹង" មាសទឹកដប់វិញ និង កែប្រែចំណុចពន្ធសមាមាត្រពីមួយភាគរយលើទឹកប្រាក់ ៥០ តម្លឹង មកជាមួយភាគរយលើទឹកប្រាក់ ៤៥តម្លឹងមាសវិញ ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីធានាសាលាឧទ្ធរណ៍ចំនួន ១៣.០០០រ៛០០ ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ុំង២.៥៥០រ៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រ៛០០ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រ៛០០ និង លើអាជ្ញាធរតុលាការ ៥.០០០រ៛០០ សរុប ១៣.០០០រ៛០០ ។

៤- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី ទើបក្លាយជាស្ថាពរក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៤១៩ ចុះថ្ងៃទី ០៧-១២-៩៨ របស់លោក សេង ហុង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាការពាររបស់ឈ្មោះ សេង ហុង ចុះថ្ងៃទី ១៧-២-៩៩ ។

បានឃើញសារណាតបរបស់ឈ្មោះ អៀង ថុង ចុះថ្ងៃទី ០៧-៣-៩៩ ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :-សាលដីកាសាលាឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ សេង ហុង ដែលបានឆ្លើយនៅពេលសវនាការថា :-ការកាត់របស់សាលាឧទ្ធរណ៍មិនត្រឹមត្រូវ ហើយ កំណត់ហេតុរបស់ក្រុមពន្លត់អគ្គីភ័យក៏មិនត្រឹមត្រូវដែរ ផ្ទះខ្លួនគ្មានកន្លែងរុជធូប គ្មានភ្លើងអគ្គិសនីទេ ។ តាមសាក្សីគេថាឆេះពីខាងលើផ្ទះ អៀងថុងតែម្ដង ។ សុំលោកប្រធានបដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ អៀង ថុង ដែលបានឆ្លើយនៅពេលសវនាការថា :-មូលហេតុអ្វីបានជា សេង ហុង មិនយកសោរទៅផ្ញើឪពុកដែលនៅផ្ទះជិតហ្នឹង បែរជាផ្ញើផ្ទះអ្នកដទៃ ។ ហើយពេលឆេះហេតុអ្វីបានជាឪពុកមិនអោយកូនប្រាំងអគ្គីភ័យទៅ សោរចូលពន្លត់ គឺប្រហែលជាមានគំរោងទុកជាមុន ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោក ពែម ខុន មេធាវីថុងចម្លើយនៅពេលសវនាការ

ថា :_តុលាការថ្នាក់ក្រោមកំណត់ និង វាយតម្លៃការខូចខាតតាមរបាយការណ៍ របស់ ការិយាល័យ នគរបាលអគ្គីភ័យលេខ ០៤៩ ចុះថ្ងៃទី ២៥_០១_៩៣ ព្រោះរបាយការណ៍នេះបានយកតាមចម្លើយរបស់ដើម រងគ្រោះទាំងស្រុង ។

_ការសំរេចអោយកូនក្តីខ្លួនធានាសំណង និង សំណងជម្ងឺចិត្ត គឺ ខុសទាំងស្រុង ព្រោះកូនក្តីរបស់ខ្លួន គ្មានកំហុសទេ តាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៤១៦ ចុះថ្ងៃទី ២១_១០_៩៤ របស់ តុលាការ ក្រុងភ្នំពេញ ។

_ខ្លួនសុំក្រុមប្រឹក្សាជំនុំជំរះ មេត្តាសំរេចបដិសេធសាលដីកាលេខ ៣៨៤ ចុះថ្ងៃទី ១៦_១០_៩៥ របស់ សាលាឧទ្ធរណ៍ចោលជាអសារបង់ ដោយបដិសេធរឿងនេះទៅអោយសាលាឧទ្ធរណ៍ធ្វើការ ស៊ើបអង្កេតឡើងវិញ ។

- ព្រោះពុំបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ព្រោះពុំបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ព្រោះពុំបានស្តាប់ចម្លើយដោះសាររបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវី ចុងចម្លើយ
- ព្រោះពុំបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុ លា កា រ កំ ពូ ល

_ យល់ឃើញថាបណ្តឹងសាទុក្ខលេខ ៤១៩ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់លោក_ សេង ហុង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ៩៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់ សាលាជំរះក្តី ។

_ យល់ឃើញថា ការដែលមានអគ្គីភ័យកើតឡើង នៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៣ បណ្តាលអោយឆេះផ្ទះរបស់លោក អៀង ថុង នោះគឺមានសាក្សីឃើញច្បាស់លាស់ថា ភ្លើងឆេះចេញពីផ្ទះរបស់លោក សេង ហុង ពិតមែន នៅពេលដែលលោក សេង ហុង ទើបតែចេញ ពីផ្ទះកើតហេតុបានប្រហែល ៥នាទីប៉ុណ្ណោះ ។

_ យល់ឃើញថា នៅពេលអគ្គីភ័យកើតឡើងភ្លាមនោះ នគរបាលអគ្គីភ័យ នៃ ស្នងការ ដ្ឋាននគរបាល ក្រុងភ្នំពេញ បានចុះដល់កន្លែងកើតហេតុហើយបានធ្វើរបាយការណ៍ និង វាយតម្លៃនៃការ អន្តរាយយ៉ាងច្បាស់លាស់ ដែលអាចយកជាការបាន ។

_ យល់ឃើញថា ការលើកឡើងរបស់លោក សេង ហុង ក្នុងសារណាចុះថ្ងៃទី១៧_២_ ១៩៩៩ ថាភ្លើងឆេះនេះ មិនដឹងបណ្តាលមកពីមូលហេតុអ្វីឡើយ ព្រោះគ្រួសារខ្លួនសុទ្ធតែពុំនៅ ផ្ទះ ហើយថាលោក អៀង ថុង ជាអ្នកបំភ្លឺសការពិតនោះ ជាការពុំត្រឹមត្រូវឡើយ ពីព្រោះ មានភស្តុតាងច្បាស់លាស់ បញ្ជាក់ថាភ្លើងឆេះចេញពីផ្ទះលោក សេង ហុងមែន ។

_ យល់ឃើញថា ការដែលមេធាវីចុងចម្លើយ អះអាងថាកូនក្តីលោកត្រូវបានតុលាការ

ក្រុងភ្នំពេញ អោយរួចផុតពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ដូច្នេះកូនក្តីលោក ពុំត្រូវមានកាតព្វកិច្ច សងការខូចខាតនោះជាការភ័ន្តច្រឡំពីព្រោះថាថ្វីបើ កូនក្តីលោក ពុំត្រូវចោទប្រកាន់ពីបទបង្កអគ្គីភ័យដោយចេតនាក៏ពិតមែន ប៉ុន្តែកូនក្តីលោកត្រូវទទួលខុសត្រូវដូចដែលកំណត់ក្នុងមាត្រា ១៦១ នៃក្រិត្យ-ច្បាប់លេខ ៣៨ក្រ-ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យាដដែល ពីព្រោះប្រភព នៃ អគ្គីភ័យនេះគឺចេញពីផ្ទះរបស់កូនក្តីលោក ។

- យល់ឃើញថា សាលដីកាជំនុំជំរះលេខ ៧៥០ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទម្រង់ និង គតិច្បាប់ហើយ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ៤១៩ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់ លោក សេង ហុង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាជំនុំជំរះលេខ៧៥០ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទ បានបង់ដូលទុកនៅ តុលាការកំពូល ចំនួន ១៦.០០០៛០០ គឺ :-

-ពន្ធចុះបញ្ជីក្តី និងពន្ធតែម ចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន - ៨០០៛០០ សម្រាប់ដាក់ផ្ញើក្រឡាបញ្ជីការទទួលប្រាក់ ,

-ចំណាយក្នុងការប្រគល់ដីកានោះចំនួន ១២.០០០៛០០ សរុប ១៦.០០០៛០០ ហើយត្រូវអោយចុងចម្លើយសងប្រាក់នេះ ទៅដើមចោទវិញ ។

-បង្គាប់អោយលោក សេង ហុង បង់ពន្ធសោហ៊ុយតាមការសំរេចរបស់ តុលាការថ្នាក់ក្រោម ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៩ ។